# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ១៦ ខែ មករា ឆ្នាំ២០១២

## ជប៉ុនផ្តល់ ៨៦,១៦៦ ដុល្លារអាមេរិក សម្រាប់ការសាងសង់ផ្លូវកសិកម្ម ក្នុងខេត្តបាត់ដំបង

ក្រោមគ្រោងការណ៍នៃជំនួយឧបត្ថម្ភឥតសំណងសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុន រដ្ឋាភិបាលជប៉ុន បានផ្តល់ទឹកប្រាក់សរុបចំនួន **៨៦,១៦៦ ដុល្លាអាមេរិក** ដល់អង្គការ Good Earth Japan (ជី អ៊ី ជេ) សម្រាប់គម្រោងសាងសង់ផ្លូវកសិកម្មក្នុងភូមិគោកជ័រ និងភូមិអណ្តើក១១ ឃុំស្តៅ ស្រុករតនមណ្ឌល ខេត្តបាត់ដំបង។ កិច្ចសន្យាផ្តល់ជំនួយត្រូវបានចុះហត្ថលេខានៅថ្ងៃនេះដោយឯកឧត្តមលោកម៉ាសាហ្វូមី គូរ៉ូគី ឯកគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព របស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និង លោកម៉ូរី តេស៊ឹអ៊ុ តំណាងប្រចាំប្រទេស អង្គការ ជី អ៊ី ជេ នៅស្ថានទូតជប៉ុន។

អង្គការ ជី អ៊ី ជេ នឹងអនុវត្តគម្រោងសាងសង់ផ្លូវជនបទ ដើម្បីសម្រួលដល់ការធ្វើដំណើរ ក្នុងភូមិគោកជ័រ និងភូមិអណ្តើក១១ ឃុំស្តៅ ស្រុករតនមណ្ឌល ខេត្តបាត់ដំបង។ ជាងនេះទៅទៀត អង្គការ ជី អ៊ី ជេ នឹងផ្តល់ការបណ្តុះបណ្តាលដល់ប្រជាពលរដ្ឋឲ្យយល់អំពីសារៈសំខាន់នៃការថែរក្សាផ្លូវ។ នៅពេលគម្រោងនេះត្រូវបានបញ្ចប់ ការធ្វើដំណើរនៅក្នុងតំបន់គោលដៅនឹងមានភាពប្រសើរឡើង ហើយយើងរំពឹងថាប្រជាពលរដ្ឋប្រមាណ៨០០នាក់ អាចបង្កើនសកម្មភាពសេដ្ឋកិច្ចរបស់ពួកគេ។

កម្មវិធីគម្រោងជំនួយឥតសំណងសម្រាប់អង្គការក្រៅរដ្ឋាភិបាលជប៉ុនបានចាប់ផ្តើមនៅប្រទេសកម្ពុជា តាំងពីឆ្នាំ២០០២ ដើម្បីគាំទ្រសកម្មភាពរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុនក្នុងកិច្ចខំប្រឹងប្រែងដើម្បីជួយដល់ការអភិវឌ្ឍន៍ និង ស្តាបនាប្រទេសកម្ពុជាឡើងវិញនៅតាមកំរិតមូលដ្ឋាន។ ចាប់តាំងពីឆ្នាំ២០០២ រដ្ឋាភិបាលជប៉ុន បានផ្តល់ថវិកាជាង១៥លានដុល្លាអាមេរិកដល់គម្រោង៦៤ របស់អង្គការក្រៅរដ្ឋាភិបាលជប៉ុនដែលផ្តោតសំខាន់ទៅលើវិស័យអប់រំនៅកម្រិតមូលដ្ឋាន វិស័យសុខាភិបាល និង សកម្មភាពបោសសំអាតមីន។ គម្រោងរបស់អង្គការ ជី អ៊ី ជេ នេះគឺជាគម្រោងទី៥ តាមរយៈគ្រោងការណ៍នៃជំនួយនេះសម្រាប់ឆ្នាំសារពើពន្ធឆ្នាំ២០១១របស់ជប៉ុន (មេសា ២០១១ ដល់ មិនា ២០១២)

---


*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*

*ទូរសព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០*

*អ៊ីមែល: eco.jpn@.pp.mofa.go.jp*

*គេហទំព័រ: http://www.kh.emb-japan.go.jp*